# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 1328

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការកសាងភាពជាដៃគូប្រទេសអាស៊ី សម្រាប់ព័ត៌មានភូមិសាស្ត្រនៃការបំពុលខ្យល់

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 17/01/22 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/01/25 |
| ៣. ចំណាយគម្រោងសរុប | $200,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងបរិស្ថាន |
| RESPONSIBLE UNIT | Directorate General of Environmental Protection, Department of Air Quality, Noise and Vibration Management |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានគាំពារបរិស្ថាន នាយកដ្ឋានគ្រប់គ្រង គុណភាពខ្យល់ សំឡេង និងរំញ័រ |
| ៥. ស្ថានភាពគម្រោង | គម្រោងកំពុងដំណើរការ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទានៈ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងជួយដល់មន្ត្រីជំនាញក្នុងការតាមដានគុណភាពខ្យល់សាធារណៈ និងជួយដល់ប្រជាពលរដ្ឋយល់ដឹងបន្ថែមអំពីស្ថានភាពគុណភាពខ្យល់ នឹងចូលរួមចំណែកកាត់បន្ថយការបំពុលខ្យល់ក្នុងបរិយាកាស ព្រមទាំងយល់ដឹងបន្ថែមកាន់តែច្បាស់អំពីផលប៉ះពាល់នៃការបំពុលខ្យល់ទៅលើបរិស្ថាន និងសុខភាពសារធារណៈ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ដើម្បីពង្រឹងសមត្ថភាពថ្នាក់តំបន់ និងថ្នាក់ជាតិដើម្បីអនុវត្តការវិភាគទិន្នន័យដែលបានពីបណ្តាញនៅលើដី និង ក្នុងបរិយាកាសក៏ដូចជាបំពេញកង្វះខាតទិន្នន័យ និងព័ត៌មាន ក្នុងការតាមដានគុណភាពខ្យល់ទូទាំងប្រទេស ជាពិសេស ការធ្វើសមាហរកម្ម និងធ្វើឱ្យមានសុពលភាពទិន្នន័យ GEMS (The Geostationary Environment Monitoring Spectrometer) ជាមួយនឹងព័ត៌មានតាមដាននៅតាមទីតាំងនីមួយៗ និងដើម្បីធ្វើឱ្យប្រសើរឡើងការយល់ដឹងពីការ បំពុលខ្យល់ ការប្រើប្រាស់ម៉ូដែលតាមដានគុណភាពខ្យល់សម្រាប់វិភាគ ព្យាករណ៍ស្ថានភាពគុណភាពខ្យល់ និង សេវាព្រមាន។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

១. ការរៀបចំជាដៃគូថ្នាក់តំបន់តាមរយៈបណ្តាញ PANDORA អាស៊ី
២. រៀបចំបង្កើតទម្រង់ទិន្នន័យ (Platform) ថ្នាក់អនុតំបន់ និងថ្នាក់ជាតិដើម្បីគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យ
៣. ពង្រឹងសមត្ថភាពមន្ត្រីជំនាញតាមរយៈកម្មវិធីបណ្តុះបណ្តាល ស្តីពីការដំឡើង និងប្រើប្រាស់ឧបករណ៍ PANDORA ជាពិសេសយល់ដឹងអំពីការគ្រប់គ្រងទិន្នន័យតាមដានគុណភាពខ្យល់តាមប្រព័ន្ធផ្កាយរណប។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

• ជួយបំពេញទិន្នន័យតាមដានគុណភាពខ្យល់សាធារណៈ ដែលចន្លោះប្រហោង នៅទីតាំងដែលក្រសួងបរិស្ថាន មិនទាន់បានដំឡើងឧបករណ៍តាមដានគុណភាពខ្យល់
• ផ្តល់ទិន្នន័យគុណភាពខ្យល់ សម្រាប់ជំនួយដល់ការវាយតម្លៃ ការពង្រឹងការគ្រប់គ្រងគុណភាពខ្យល់ ការធ្វើ ម៉ូដែលចលនាសារធាតុបំពុលខ្យល់ក្នុងប្រទេស និងតំបន់ និងការធ្វើសារពើភ័ណ្ឌការបញ្ចេញសារធាតុបំពុលខ្យល់
• ទទួលបានឧបករណ៍ និងបច្ចេកវិទ្យាទំនើបក្នុងការតាមដានគុណភាពខ្យល់
• ផ្តល់ចំណេះដឹង និងបទពិសោធន៍ដល់មន្ត្រីជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការតាមដាន គុណភាពខ្យល់
• ពង្រឹងកិច្ចសហប្រតិបត្តការរវាងប្រទេសក្នុងតំបន់ ក្នុងការតាមដាន និងគ្រប់គ្រងការបំពុលខ្យល់នៅកម្ពុជា។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

• គម្រោងនេះនឹងគាំទ្រដល់ការពង្រឹងសមត្ថភាពមន្ត្រីរបស់នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ សំឡេងនិងរំញ័រ ក្នុងការត្រួតពិនិត្យគុណភាពខ្យល់។
• គាំទ្រក្នុងការបង្កើតក្រុមការងារអន្តរក្រសួងក្នុងការអភិវឌ្ឍគោលនយោបាយនិងបទប្បញ្ញត្តិជាតិ។
• គាំទ្រដល់ការគ្រប់គ្រងគុណភាពខ្យល់សាធារណៈនិងការការពារសុខភាពសាធារណៈ។
• បង្ហាញពីជំហររបស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ ក្នុងការតាមដានគុណភាពខ្យល់ ការកាត់បន្ថយ ការបំពុលខ្យល់ និងកិច្ចគាំពារសុខភាពសាធារណៈ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

ការបំពុលខ្យល់នៅក្នុងសហគមន៍គឺងាយរងផលប៉ះពាល់ដល់ក្រុមងាយរងគ្រោះ និងជាពិសេសស្ត្រី ដែលត្រូវបាន គេចាត់ទុកថាជាធាតុចូលដ៏សំខាន់សម្រាប់គោលនយោបាយ និងការអភិវឌ្ឍបទបញ្ញត្តិ។ ដូចនេះ គម្រោងនេះ នឹងផ្តល់នូវផលវិជ្ជមានដល់សុខភាពប្រជាជននៅទីតាំងគម្រោង (ទីតាំងដំឡើងក្នុងការត្រួតពិនិត្យគុណភាពខ្យល់) ហើយក្រុមអ្នកក្រ និងក្រុមងាយរងគ្រោះនឹងទទួលបានអត្ថប្រយោជន៍សុខភាពពីវិធានការណ៍គ្រប់គ្រងការបំពុល បរិស្ថាន ដែលបានអនុវត្តដោយរដ្ឋាភិបាល។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការកាត់បន្ថយ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៤. ការកាត់បន្ថយការបញ្ចេញឧស្ម័ន** | 65 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការកាត់បន្ថយ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះ មិនប៉ះពាល់ដល់តួនាទីបុរសនិងស្ត្រីទេ ប៉ុន្តែស្ត្រីត្រូវបានចូលរួមយ៉ាងសកម្មជាមួយនិងការអនុវត្ត គម្រោងនេះ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គម្រោងនេះ នៅខ្វះខាតអ្នកជំនាញការដែលមានបទពិសោធន៍ក្នុងការដំឡើង និងប្រើប្រាស់ឧបករណ៍ ដូច្នេះគម្រោង ត្រូវការទីប្រឹក្សាបច្ចេកទេស និងអ្នកជំនាញការទាំងក្នុង និងក្រៅប្រទេស។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងបាននឹងកំពុងដំណើរការពីដើមឆ្នាំ២០២២ និងគ្រោងបញ្ចប់ចុងឆ្នាំ២០២៥**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

8

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះបានទទួលហិរញ្ញប្បទានពីគណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ សម្រាប់ អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) និងវិទ្យាស្ថានជាតិស្រាវជ្រាវបរិស្ថាន (NIER) នៃសាធារណរដ្ឋកូរ៉េ តាមរយៈ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 170.0 | 170.0 | 20.0 | 10.0 | 0.0 | 0.0 | 10.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 100.0 | 100.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 30.0 | 30.0 | 10.0 | 5.0 | 0.0 | 0.0 | 5.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 40.0 | 40.0 | 10.0 | 5.0 | 0.0 | 0.0 | 5.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 170.0 | 170.0 | 20.0 | 10.0 | 0.0 | 0.0 | 10.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 170.0 | 170.0 | 20.0 | 10.0 | 0.0 | 0.0 | 10.0 | |
| | | | | | | | | |
| Korea International Cooperation Agency | 170.0 | 170.0 | 20.0 | 10.0 | 0.0 | 0.0 | 10.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 170.0 | 170.0 | 20.0 | 10.0 | 0.0 | 0.0 | 10.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: